# ព្រះរាជាណាចក្រកម្ពុជា
## ជាតិ សាសនា ព្រះមហាក្សត្រ

# សេចក្តីសម្រេចកែសម្រួលលើកទី២
# ឯកសារអាជ្ញាប័ណ្ណរួមលេខ ០៧៥ ឯអ ចុះថ្ងៃទី១៦ ខែធ្នូ ឆ្នាំ២០០៣
# សម្រាប់លោក ឆាយ គឹមហួរ
# អាជ្ញាធរអគ្គិសនីកម្ពុជា

- អនុវត្តតាមមាត្រា ៧ និង ៣៥ របស់ច្បាប់ស្តីពីអគ្គិសនីនៃព្រះរាជាណាចក្រកម្ពុជា ដែលប្រកាសឱ្យប្រើដោយព្រះរាជក្រមលេខ នស/រកម/០២០១/០៣ ចុះថ្ងៃទី០២ ខែកុម្ភៈ ឆ្នាំ២០០១
- យោងឯកសារអាជ្ញាប័ណ្ណលេខ ០៧៥ ឯអ ដែលអាជ្ញាធរអគ្គិសនីកម្ពុជាចេញឱ្យលោក ឆាយ គឹមហួរ នៅថ្ងៃទី១៦ ខែធ្នូ ឆ្នាំ២០០៣
- យោងពាក្យស្នើសុំបន្តអាណត្តិអាជ្ញាប័ណ្ណរបស់លោក ឆាយ គឹមហួរ ចុះថ្ងៃទី០៥ ខែកញ្ញា ឆ្នាំ២០០៧
- យោងកំណត់បង្ហាញសុំបន្តអាណត្តិអាជ្ញាប័ណ្ណរបស់លេខាធិការដ្ឋានលេខ ០៥០-០៧-លជ ចុះថ្ងៃទី២៧ ខែកញ្ញា ឆ្នាំ២០០៧
- យោងតាមការពិគ្រោះយោបល់ជាមួយអ្នកពាក់ព័ន្ធ និងសាធារណជន ដែលបានធ្វើចាប់ពីថ្ងៃទី២២ ខែតុលា ឆ្នាំ២០០៧ ដល់ថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ២០០៧
- យោងតាមការអនុម័តរបស់សម័យប្រជុំរបស់ **អាជ្ញាធរអគ្គិសនីកម្ពុជា** លើកទី ១២០ ចុះថ្ងៃទី១៧ ខែមករា ឆ្នាំ២០០៨

## សម្រេច

**ប្រការ១**

ដោយលោក **ឆាយ គឹមហួរ** (បន្ទាប់ពីនេះហៅថា“**អ្នកកាន់អាជ្ញាប័ណ្ណ**”) បានកែលម្អមធ្យោបាយធ្វើសេវាកម្មអគ្គិសនីរបស់ខ្លួនបានមួយចំនួនធំ ហើយត្រូវធ្វើការកែលម្អនៅឆ្នាំបន្តបន្ទាប់ទៀត ដើម្បីឱ្យស្របតាមស្តង់ដាបច្ចេកទេសអគ្គិសនីក្នុងព្រះរាជាណាចក្រកម្ពុជា អាជ្ញាធរអគ្គិសនីកម្ពុជាសម្រេចកែសម្រួលអាជ្ញាប័ណ្ណរួម លេខ ០៧៥ ឯអ ចុះថ្ងៃទី១៦ ខែធ្នូ ឆ្នាំ២០០៣ ដែលបានផ្តល់ជូនអ្នកកាន់អាជ្ញាប័ណ្ណ ដោយបន្តអាណត្តិអាជ្ញាប័ណ្ណចំនួន ០៥(ប្រាំ) ឆ្នាំទៀត ។

**ប្រការ២**

អាណត្តិថ្មីរបស់អាជ្ញាប័ណ្ណនេះ មានរយៈពេល០៥(ប្រាំ)ឆ្នាំ គិតចាប់ពីថ្ងៃទី១៦ ខែធ្នូ ឆ្នាំ២០០៧ និងអាចស្នើសុំបន្តទៀត ឬស្នើសុំកែសម្រួលលើកលែងតែ ត្រូវដក ហូតដោយអនុលោមតាមល័ក្ខខ័ណ្ឌនៃអាជ្ញាប័ណ្ណនេះ ។

**ប្រការ៣**

សេចក្តីសម្រេចនេះ ត្រូវក្លាយជាផ្នែកមួយនៃឯកសារអាជ្ញាប័ណ្ណលេខ ០៧៥ ឯអ ។

**ប្រការ៤**

ខ្លឹមសារ និងល័ក្ខខ័ណ្ឌដទៃទៀតនៃឯកសារអាជ្ញាប័ណ្ណលេខ ០៧៥ ឯអ ត្រូវស្ថិតនៅជាធរមានដដែល ។

**ប្រការ៥**

សេចក្តីសម្រេចនេះ ត្រូវចូលជាធរមាន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

**ប្រការ៦**

អ្នកកាន់អាជ្ញាប័ណ្ណ ត្រូវផ្ញើសេចក្តីសម្រេចនេះទៅតម្កល់ទុកបន្ថែមនៅតាមទី កន្លែងដែលឯកសារអាជ្ញាប័ណ្ណលេខ ០៧៥ ឯអ បានតម្កល់ទុកពីមុន ដើម្បីឱ្យឯកសារអាជ្ញាប័ណ្ណលេខ ០៧៥ ឯអ ដែលតម្កល់មានការកែសម្រួលជាថ្មីស្របតាមសេចក្តីសម្រេចនេះ ។

ភ្នំពេញ, ថ្ងៃទី១៧ ខែមករា ឆ្នាំ២០០៨

**ប្រធានអាជ្ញាធរអគ្គិសនីកម្ពុជា**

លក្ខខ័ណ្ឌរបស់អាជ្ញាប័ណ្ណនេះមានខ្លឹមសារដូចអាជ្ញាប័ណ្ណលេខ ០១៥.ឯអ ចុះថ្ងៃទី២២ ខែវិច្ឆិការ ឆ្នាំ២០០២ ។ប្រសិនបើចង់ពិនិត្យមើលខ្លឹមសារ សូមពិនិត្យមើលផ្នែកទី២ របស់អាជ្ញាប័ណ្ណនេះ ។